# បងអប់រំខ្ញី

## ស្តីអំពី: "សារសំខាន់នៃការដឹកនាំ"




ការធ្វើអ្វីមួយ ត្រូវមានគំនិតគិតឲ្យបានច្បាស់មុននឹងសម្រេចថាធ្វើ ប្រសិនបេះតែធ្វើដោយមិនបានពិចារណាឲ្យហ្មត់ចត់ទេនោះ ច្បាស់ជាត្រូវខាតបង់ប្រយោជន៍គ្រប់យ៉ាង។

ជាបន្តទៅទៀតនេះ ខ្ញុំនឹងមានពាក្យស្លោកមកអធិប្បាយពាក្យស្លោកទាំងនេះ គឺជាបណ្តាំរបស់បណ្ឌិតធនជ័យមុននឹងគាត់ស្លាប់ទៅ បានផ្តាំជាមួយនឹងស្តេចថា "បើប្រសិនជាព្រះអង្គសោយត្រីព្រួល កុំចោលស្រកា បើសោយត្រីប្រា កុំចោលស្រកី ស្មោរក្បាលត្រីសណ្តាយ កុំចោលម្លួរសណ្តាន់"



ក្នុងពាក្យស្លោកនេះ មិត្តអ្នកអានប្រហែលជាបានទស្សនារួចមកហើយនូវរឿងបណ្ឌិតធនជ័យ បានផ្តាំចំពោះអ្នកដឹកនាំត្រូវមានគោលធម៌សម្រាប់ដឹកនាំឲ្យបានសុខសាន្តរីកចម្រើន អត្ថន័យពាក្យទាំងបីនេះ

ខ្ញុំនឹងអធិប្បាយឲ្យមិត្តអ្នកអាន បានដឹងច្បាស់អំពីពាក្យទាំងនេះដូចចតទៅ ។

១. ពាក្យថា សោយត្រីព្រួល កុំចោលស្រកា ន័យត្រង់ ត្រីព្រួលរស់បានដោយសារស្រកា ព្រោះស្រកាជាគ្រឿងបិទបាំងរាងកាយនៃត្រី ន័យបង្កប់ ស្រកាប្រៀបដូចជា ប្រជារាស្ត្រដែលរស់នៅជុំវិញអ្នកដឹកនាំដោយគុណធម៌ និងន័យបង្កប់មួយទៀត ប្រសិនបើ មិនចង់ឲ្យអំណាចដឹកនាំរបស់ខ្លួនប្រែប្រួលឬប្រួលប្រែទេគ្រប់អ្នកដឹកនាំត្រូវគិតប្រយោជន៍ស្រកាគឺប្រជារាស្ត្រ ព្រោះរាស្ត្រអាចលើកបុគ្គលម្នាក់



ឲ្យធ្វើអ្នកដឹកនាំបានហើយ ក៏អាចទម្លុះទម្លាយនូវអំណាចដឹកនាំបុគ្គលនោះ ឲ្យប្រួលប្រែក្រឡាប់ចក្របាន នេះជាន័យក្នុងប្រស្នាទីមួយដែលធនជ័យបណ្ឌិតបានផ្តាំអ្នកដឹកនាំគ្រប់រូប ។

២. សោយត្រីប្រា កុំចោលស្រកី ដូចបានពន្យល់រួចមកហើយនូវប្រស្នាទីមួយន័យត្រង់ស្រកីគឺនៅនឹងក្បាល ស្រកីជាច្រមុះដង្ហើមរបស់ត្រី ត្រីប្រាអាចរស់បាន គឺដោយសារច្រមុះសម្រាប់ដកដង្ហើម ឥតមានស្រកីទុកដូចស្លាប់ ន័យបង្កប់នគរមួយអាច



រស់បានដោយឯកពជ្យ ដោយពឹងផ្អែកទៅលើសេដ្ឋកិច្ច ព្រោះសេដ្ឋកិច្ចគឺជាភាពខ្លាំងក្លារបស់នគរនីមួយៗ ឬដូចជាគ្រួសារមួយអាចមានសេចក្តីសុខសមរម្យបាន គឺស្ត្រីជាអ្នកផ្គុំទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យគង់វង្សទើបអាចក្លាយជាអ្នកបរិបូណ៌ ដោយទ្រព្យពាក្យថាស្រកីក្លាយមកពីពាក្យត្រឡាប់ថាស្រីក មានន័យថា បើស្រីកទុក្ខគឺបានទុក្ខ បើស្រីកសុខគឺបានសុខនិងសុភមង្គល ន័យបង្កប់ទីពីរគឺប្រាស្រ័យទាក់ទងសង្គមជាតិមួយអាចរីកចម្រើនទៅបាន អ្នកដឹក-នាំត្រូវចេះអាស្រ័យទាក់ទងឲ្យដឹងថា សួរសុខទុក្ខពីក្រោមទៅលើពីតូចទៅធំ ពីទាបទៅខ្ពស់ ពីក្នុងប្រទេសទៅក្រៅប្រទេស ដើម្បីចម្រាញ់និងនាំយកនូវអ្វីដែលថ្មី នឹងជឿនលឿនសម្រាប់យកមកកសាងមាតុភូមិរបស់ខ្លួនឲ្យបានរីកចម្រើន ដូចអត្ថន័យក្នុងប្រស្នាថា "សោយត្រីប្រា កុំចោលស្រកី" ក្បាលត្រូវ

ច្រេះគិត គិតអំពីដង្ហើមរស់សម្រប់ចិញ្ចឹមខ្លួនត្រីទាំងមូល ។



៣. ស្មោរក្បាលត្រីសណ្តាយ កុំចោលម្ជូរសណ្តាន់ន័យត្រង់នេះ បើយើងស្មោរក្បាលត្រីត្រូវប្រើម្ជូរសម្រាប់កាត់នូវចម្អាប ហេតុអ្វីបានជាមិនយកម្ជូរដទៃ បែរជាយកម្ជូរសណ្តាន់មកដាក់ជាប្រស្នា ព្រោះពាក្យសណ្តាន់ និងសណ្តានដែលជាពាក្យតំណាងញាតិ មានសូរស័ព្ទស្រដៀងគ្នាសម្រាប់ចងជាប្រស្នាបំភ័ណ ន័យបង្កប់គាត់ចង់ប្រាប់អ្នកដឹកនាំគ្រប់ជំនាន់ថា បើយើងគ្រប់គ្រងនគរត្រូវសំឡឹងមើលកូនចៅ ឬញាតិរបស់ខ្លួនព្រោះភាគច្រើននៃញាតិ

តែងយកអំណាចរបស់ អ្នកដឹកនាំទៅប្រើគំរាមកំហែងអ្នកនៅក្រោមផ្តេសផ្តាស ទៅតាមចិត្តលោកលន់របស់ខ្លួន ដែលធ្វើឲ្យអ្នកនៅខាងក្រោមអំណាចរងទុក្ខវេទនា ដោយសារមនុស្សអគតិមួយចំនួនគ្មានការគិតអំពីប្រជារាស្ត្រដែលគ្នា គ្មានកម្លាំងតបតទៅវិញ គ្រប់អ្នកដឹកនាំទាំងឡាយត្រូវប្រើប្រាស់ច្បាប់ត្រឹមត្រូវប្រកបដោយយុត្តិធម៌ គឺម្ជូរសម្រាប់កាត់នូវចម្អាបគឺក្លិនមិនល្អ ដែលញាតិរបស់ខ្លួនបានធ្វើឲ្យ



ខូចសណ្ដាប់ធ្នាប់ក្នុងសង្គម ព្រោះយកអំណាចមកប្រើតាមទំនើងចិត្តជាពិសេស ធ្វើឲ្យកើតនូវគំនុំគំកួនចំពោះអ្នកដឹកនាំ ដែលមានញាតិមិនល្អធ្វើឲ្យកម្លាំងរាស្ត្រ ដែលរងគ្រោះត្រូវរកវិធីរំលាយអំណាចបុគ្គលនោះចោល នេះជាហេតុធនជ័យបណ្ឌិតយកឈ្មោះមួរសណ្ដាន់មកបញ្ចប់ប្រស្នាចុងក្រោយ មុនពេលគាត់ស្លាប់ បើយើងគ្រាន់តែមើលដោយមិនបានគិតពិចារណារឿង គឺត្រឹមតែស្ដាប់រួចហើយសើចសប្បាយ បើយើងទស្សនាត្រូវយកមកពិចារណាប្រកបដោយយោនិសោមនសិការនោះ លើកយកពោធិសត្វលោកកេស្វរៈ ដែលមានឈ្មោះល្បីល្បាញនេះយើងធ្លាប់ឮនិងស្គាល់ឈ្មោះគាត់ ក្នុងសម័យអង្គរនេះឯង គឺព្រះបាទជ័យវរ្ម័នទី៧ ។



សរុបសេចក្ដីឲ្យខ្លីមក គ្រប់អ្នកដឹកនាំគ្រប់រូប ត្រូវមានទសពិធរាជធម៌ យកមកគ្រប់គ្រងនគររបស់ខ្លួន កុំប្រើអំណាចជើរជិះជាន់រាស្ត្រតូចតាច ដែលគ្នាគ្មានកម្លាំងតបទៅវិញ កុំលោភនិងអំណាចរបស់ខ្លួន ត្រូវមើលអ្នកនៅខាងក្រោមផង៕



*រៀបរៀងចងក្រងដោយសាមណេរ*

*សុវណ្ណប្បញ្ញោ ស្វាត់ សុផើត*

ព្រះមហាធម្មាលង្ការ ចាន់ សុជន

ប្រធានកម្មវិធីណាថីសំឡេងព្រះធម៌

វត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)

ចានពិនិត្យ និងឯកភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)*

*ថ្ងៃ៨កើត ខែផល្គុន ព.ស.២៥៥៨*

*ត្រូវនឹងថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤*